01617021

E467/5

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 21 / 05 / 2019
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

## អង្គបុរេជំនុំជម្រះ

## អនុស្សរណៈ អន្តរការិយាល័យ

ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩

**ជូនចំពោះ៖ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង**

**ពី៖ ចៅក្រមនៃអង្គបុរេជំនុំជម្រះ**

**កម្មវត្ថុ៖ ចំលើយតបចំពោះអនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង "សំណើចំណាត់ថ្នាក់ប្រភេទឯកសារសំខាន់នៅក្នុងសេចក្ដីសម្រេចសំណុំរឿង០០២/០២ នៅជាសាធារណៈ"**

1. ឆ្លើយតបទៅនឹងអនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ ចៅក្រមនៃអង្គបុរេជំនុំជម្រះ កត់សម្គាល់ជាបឋមថា ឯកសារមួយចំនួនដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញរួចហើយដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។

2. ចំពោះឯកសារសម្ងាត់ដែលពុំទាន់បានធ្វើចំណាត់ថ្នាក់ឡើងវិញ ចៅក្រមនៃអង្គបុរេជំនុំជម្រះ ពុំមានបញ្ហាចំពោះការធ្វើចំណាត់ថ្នាក់ឡើងវិញឡើយ ដោយសូមរក្សាទុកជាសម្ងាត់ដដែល នូវឈ្មោះ និងពត៌មានផ្ទាល់ខ្លួនរបស់សាក្សីដែលស្ថិតក្រោមវិធានការការពារ ឬរបស់អ្នកដែលសំណើសុំវិធានការការពាររបស់គាត់កំពុងរង់ចាំការសម្រេច។ ដូច្នេះវាសមស្របទៅនឹងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះអំពីការចំណាត់ថ្នាក់ប្រភេទឯកសារឡើងវិញ នៅក្នុងសំណុំរឿង ០០៤/១។[1]

[1] *សូមមើល* សំណុំរឿង ០០៤/១ (អបជ៤៩) សេចក្ដីសម្រេចចំពោះបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងសេចក្ដីសម្រេចអំពីការកោសលុប ឬ ជាជម្រើស សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារលេខ D309/2/1/7 ; សំណុំរឿង ០០៤/១ (អបជ៥៤) សេចក្ដីសម្រេចចំពោះសំណើធ្វើចំណាត់ថ្នាក់ប្រភេទឯកសារឡើងវិញនៃចំលើយតបរបស់ អ៊ឹម ចែម ចំពោះសេចក្ដីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអជ្ញាអន្តរជាតិ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារលេខ D304/6/4។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

3. ដើម្បីឱ្យស្របនឹងយុត្តិសាស្ត្រនេះផងដែរ តាមមាត្រា៩ និងមាត្រា១២.២ នៃសេចក្តីណែនាំអនុវត្តអំពីចំណាត់ថ្នាក់ឯកសារ ចៅក្រមនៃអង្គបុរេជំនុំជម្រះស្នើសុំជាបន្ថែមចំពោះអង្គជំនុំជម្រះសាលាដំបូង ធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញចំពោះរាល់សេចក្តីសម្រេចផ្សេងទៀតរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង០០២ ដែលបច្ចុប្បន្នជាប្រភេទសម្ងាត់ ទៅជាសាធារណៈ ដោយរក្សាទុកជាសម្ងាត់ដដែល នូវឈ្មោះ និងពត៍មានផ្ទាល់ខ្លួនរបស់សាក្សីដែលស្ថិតក្រោមវិធានការការពារ ឬរបស់អ្នកដែលសំណើសុំវិធានការការពាររបស់គាត់កំពុងរង់ចាំការសម្រេច។[2]

[2] សូមមើល ឧបសម្ព័ន្ធសម្រាប់បញ្ជីរាយឈ្មោះ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង០០២ ដែលបច្ចុប្បន្ននេះជាប្រភេទសម្ងាត់ ឬសាធារណៈកោសលុប។